# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា

## ការិយាល័យផ្នែកកុមារមុនថ្នាក់មត្តេយ្យ

### ថ្នាក់មត្តេយ្យ និងក្មេងដែលចាប់ផ្តើមរៀនថ្នាក់ទី១

<u>កម្មវិធីថ្នាក់មត្តេយ្យទាំងអស់ រៀនពេញមួយថ្ងៃ។</u>

**ម៉ោងសម្រាប់ថ្នាក់មត្តេយ្យ៖** ច្បាប់នៃបទបញ្ញារបស់រដ្ឋដែលគ្រប់គ្រងលើការបង្រៀនថ្នាក់មត្តេយ្យ បានចែងថា ថ្នាក់មត្តេយ្យដែលរៀនពេញមួយថ្ងៃ ត្រូវតែផ្តល់ការបង្ហាត់បង្រៀនយ៉ាងហោចណាស់ប្រាំ (៥) ម៉ោង ក្នុងមួយថ្ងៃ គឺ ៩០០ម៉ោង ១៨០ថ្ងៃ ក្នុងមួយឆ្នាំ។ បើសិនជាសិស្សថ្នាក់មត្តេយ្យគ្រប់រូប ធ្វើមិនបានតាមតម្រូវការនេះទេ ក្រសួងអាចបាត់បង់ប្រាក់ជំនួយ។

**អាយុ**

- សម្រាប់ថ្នាក់មត្តេយ្យ ក្មេងត្រូវតែមានអាយុ ៥ឆ្នាំ នៅថ្ងៃ ឬមុនថ្ងៃទី១ ខែកញ្ញា។
- សម្រាប់ថ្នាក់ទី១ ក្មេងត្រូវតែមានអាយុ ៦ឆ្នាំ ដែលត្រូវទៅរៀនដោយខានមិនបាន នៅថ្ងៃ ឬមុនថ្ងៃទី១ ខែកញ្ញា។
- លិខិតបញ្ជាក់ភស្តុតាងពីអាយុរបស់សិស្សត្រូវដាក់មកជាមួយលិខិតដាក់ពាក្យសុំចូលរៀននេះ។
- **លិខិតបញ្ជាក់ភស្តុតាងពីអាយុដែលគេទទួលស្គាល់** (ឯកសារណាមួយក្នុងចំណោមឯកសារទាំងនេះ)៖
  - សំបុត្រកំណើតជាផ្លូវការ សំបុត្រចូលសាសនា សំបុត្រឆ្លងដែនរបស់សិស្សដែលកើតនៅបរទេស ឯកសារជាតឹកតាងផ្សេងទៀត (សំបុត្រសុំក្មេងមកចិញ្ចឹម ឯកសារពីតុលាការរកន្លែងឲ្យក្មេងនៅ ឯកសារពីមន្ទីរពេទ្យ ឯកសារពីស្ថាប័នចិញ្ចឹមកុមារ ឯកសារពីអង្គការសង្គមកិច្ច ឬអត្តលេខអ្នកអន្តោប្រវេសន៍ (alien number) លេខលិខិត I-94 និង ឯកសារចាក់ថ្នាំបង្ការពោគថ្មីៗ។
- ក្មេងដែលមានអាយុ ៦ឆ្នាំណាដែលមិនបានទៅរៀន**ថ្នាក់មត្តេយ្យ** អាចចូលរៀនថ្នាក់មត្តេយ្យ ជំនួសថ្នាក់ទី១ តាមការសរសេរលិខិតស្នើសុំពីមាតាបិតា។

**អត្តសញ្ញាណប័ណ្ណ**

- ប័ណ្ណបើកបររថយន្ត ប័ណ្ណសម្គាល់ខ្លួនដែលមិនមែនជាប័ណ្ណបើកបររថយន្ត ថ្មីៗ
- អត្តសញ្ញាណប័ណ្ណធ្វើការឲ្យ រដ្ឋសហព័ន្ធ រដ្ឋ ឬទីក្រុង តាមផ្លូវការ
- លិខិតឆ្លងដែន

**ទីលំនៅ**

- ត្រូវតែចុះឈ្មោះកូននៅសាលាដែលនៅក្នុងតំបន់ ទោះបីជាកូនរបស់លោកអ្នកមិនទៅរៀននៅសាលាដែលនៅក្នុងតំបន់ ដោយសារមាន តម្រូវការពិសេស ពិការភាព ផ្លាស់ប្តូរសាលា ឬ នៅក្នុងករណីលើកលែង ក៏ដោយ។
- ក្មេងត្រូវតែរស់នៅក្នុងតំបន់នៃសាលាដែលពួកគេដាក់ពាក្យសុំចូលរៀន។
- លិខិតបញ្ជាក់ភស្តុតាងពីទីលំនៅ ត្រូវដាក់មកជាមួយលិខិតដាក់ពាក្យសុំចូលរៀន។
- **លិខិតបញ្ជាក់ភស្តុតាងពីទីលំនៅដែលគេទទួលស្គាល់** (ឯកសារណាមួយក្នុងចំណោមឯកសារទាំងនេះ)៖
  - សំបុត្របង់ថ្លៃ (ភ្លើង ហ្គែស ទឹក) ថ្មីៗ ប័ណ្ណប្រើសម្រាប់បោះឆ្នោតបច្ចុប្បន្ន ច្បាប់ដើមនៃកិច្ចព្រមព្រៀងជួលផ្ទះ(ត្រូវវាយអក្សរពុម្ពចុះហត្ថលេខា ដោយអ្នកដែលពាក់ព័ន្ធទាំងអស់ និងបោះត្រាបញ្ជាក់) ប័ណ្ណកម្មសិទ្ធ លិខិតបញ្ជាក់ភស្តុតាងពីកន្លែងរស់នៅដែលបានចុះហត្ថលេខាដោយម្ចាស់ផ្ទះ/អ្នកជួលផ្ទះ ឬម្ចាស់ផ្ទះជួល ហើយបោះត្រាបញ្ជាក់។ **លិខិត បញ្ជាក់ពីការចិញ្ចឹមក្មេង/មើលថែក្មេង និងពី DHS ក៏ទទួលស្គាល់សម្រាប់ការចុះឈ្មោះដែរ ពេលណាសិស្សស្ថិតនៅក្រោមការចិញ្ចឹមបីបាច់ដោយជនណាម្នាក់/មើលថែដោយអង្គការណាមួយ លិខិតបញ្ជាក់ពីកន្លែងជ្រកកោន ឬទីលំនៅ ក៏គេទទួលស្គាល់ដែរ សម្រាប់សិស្សដែលគ្មានទីលំនៅពិតប្រាកដ។**

ដោយសារមូលហេតុនៃច្បាប់រដ្ឋសហព័ន្ធ – Plyer v. Doe [457 US 202 (1982)] – សាលាប្រហែលជាមិនអាចបដិសេធការទទួលសិស្ស ដោយយោងទៅលើការរស់នៅឥតច្បាប់បានទេ។ ច្បាប់នេះសម្រាប់អ្នកដែលមិនទាន់ចូលសញ្ជាតិអាមេរិកាំង។